

# ដំណាំល្មុត

## ១- ពូជល្មុត:

ក- ល្មុតធម្មតា ឬ ល្មុតណាំងបាយស្រោះ ផ្លែវាធំល្មម រាងទ្រវែង ផ្លែ៤ ទៅ៥ដងក្នុងមួយឆ្នាំ។

ខ-ល្មុតណាំង ឬ ល្មុតណាំងថ្ម ឬ ល្មុតថ្មះ ផ្លែល្អិតៗ ប៉ុន្តែរឹង វាផ្លែ២ ទៅ ៣ដង ក្នុងមួយឆ្នាំ។

គ- ល្មុតពូជចឹកកាយ៉ាំង ឬល្មុតតាខ្មៅះ ផ្លែធំៗ វាផ្លែ ៤ ទៅ ៥ដងក្នុងមួយឆ្នាំ ប៉ុន្តែពុំសូវមានរសជាតិឆ្ងាញ់ទេ។ គេនិយមប្រើប្រាស់វាក្នុងពិធីមង្គលការ និង បុណ្យទានផ្សេងៗ។

ឃ-ល្មុតណាំងប៉ែន ឬល្មុតណាំងខ្សាច់ះផ្លែមានរាងដូចផ្លែចាន់ប៉ែន សាច់វាទន់ជ្រាកៗបន្តិច ` ផ្លែវាធំជាង ល្មុតធម្មតាបន្តិច វាផ្លែ៤ទៅ ៥ដងក្នុងមួយឆ្នាំ។

## ២- ការរៀបចំដី និរណ្តៅដាំល្មុត:

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ ខែទៅ ១ ខែកន្លះសិន ដើម្បីអោយងាប់សត្វល្អិត និងស្មៅ រលួយបានល្អ។ យើងត្រូវភ្ជួរដីមួយលើកទៀតនៅ ពេលដែលជិតដាំកូនល្មុត។
- យើងត្រូវទាញខ្សែអោយត្រង់ដើម្បីងាយស្រួលក្នុងការដាំដំណាំផ្សេងទៀត ក្រោមដើមល្មុត។
- ចន្លោះពីដើមមួយ ទៅដើមមួយ មានប្រវែង៥ម៉ែត្រ
- កាប់រណ្តៅទំហំ ៤តឹកបួនជ្រុង និងជំរៅ ៤តឹកកាប់ យកអាចម៍ដីចេញពាក់កណ្តាលរណ្តៅ រួចទើបកាប់ បំផុសអាចម៍ដីនៅសល់អោយម៉ដ្ឋ រួចដាក់លាយជា មួយដីអាចម៍គោពុកផុយល្អ។
- ត្រូវហាលរណ្តៅទុកចោល ២ទៅ៣ថ្ងៃមុនដាំ។




## ៣- ការដាំកូនល្មុត:

- យើងត្រូវយកមែកល្មុត (មែកសាក) មកទុកនៅក្បែរៗរណ្តៅជាមុនសិន។
- យកមែកល្មុតសាកមកត្រាំទឹកឲ្យសើមបន្តិច។
- ស្រាយកញ្ចប់ផ្លាស្ទិចចេញយឺតៗដោយថ្នមៗ និងប្រុងប្រយ័ត្នជានិច្ច ដោយកុំឲ្យបែកអាចម៍ដី និងដាច់ឫសល្មុតដែលបណ្តាលឲ្យវាងាប់បាន។



- ត្រូវដាក់មែកល្មុតសាក ចូលទៅក្នុងរណ្តៅដោយថ្នមៗ ដៃម្ខាងទៀតត្រូវ ប្រមូលអាចម៏ដីលុបរណ្តៅដោយច្របាច់ដី អោយបានតូចៗលុបរោយ បំពេញ រណ្តៅដោយកប់ ដីឫស





គំរាស់ ២ធ្នាប់ដៃ ហើយនៅសល់ប្រហែល២ធ្នាប់ដៃទៀតទើបអាចម៍ដីស្មើនឹង មាត់រណ្តៅ។

- យើងមិនត្រូវជាន់បង្ហាប់ដីនៅក្នុងរណ្តៅនោះទេ។